**វិទ្យាស្ថានសភាកម្ពុជា**
**PARLIAMENTARY INSTITUTE OF CAMBODIA**
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះគឺ៖

- ធនាគារជាតិនៃកម្ពុជាជ្រើសរើសធនាគារបី ក្នុងការសាកល្បងប្រព័ន្ធប្រតិបត្តិការហិរញ្ញវត្ថុដើម្បីផ្តល់ភាពងាយស្រួលសម្រាប់ប្រតិបត្តិការជាមួយប្រទេសថៃ
- ទីផ្សារការងារនៅប្រទេសចិនប្រឈមមុខនឹងសម្ពាធនៅក្នុងសង្គ្រាមពាណិជ្ជកម្មជាមួយអាមេរិក
- កិច្ចប្រជុំកំពូល G-២០ រវាងចិន និងអាមេរិក អាចជះឥទ្ធិពលដល់ដំណើរការបន្ទាប់របស់ធនាគារកណ្តាលអាមេរិក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារជាតិនៃកម្ពុជាជ្រើសរើសធនាគារបី ក្នុងការសាកល្បងប្រព័ន្ធប្រតិបត្តិការហិរញ្ញវត្ថុ ដើម្បីផ្តល់ភាពងាយស្រួលសម្រាប់ប្រតិបត្តិការជាមួយប្រទេសថៃ

ដំណាក់ការអនុវត្តប្រព័ន្ធប្រតិបត្តិការហិរញ្ញវត្ថុមានដំណើរការយ៉ាងល្អ ក្នុងការផ្តល់ភាពងាយស្រួលដល់ប្រតិបត្តិការហិរញ្ញវត្ថុរវាងប្រព័ន្ធធនាគារកម្ពុជា និងថៃ។ នៅសប្តាហ៍នេះ ធនាគារជាតិនៃកម្ពុជាបានប្រកាសឈ្មោះធនាគារចំនួនបីដែលត្រូវបានជ្រើសរើសក្នុងការសាកល្បងប្រព័ន្ធ QR code ដែលនឹងផ្តល់ភាពងាយស្រួលដល់ប្រជាជនកម្ពុជាដែលនៅប្រទេសថៃ និងប្រជាជនថៃដែលកំពុងនៅកម្ពុជា ធ្វើការទូទាត់ដោយពុំចាំបាច់ប្រើប្រាស់សាច់ប្រាក់។ ធនាគារទាំងបីនោះរួមមានធនាគារអេស៊ីលីដា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា និងធនាគារកម្ពុជាពាណិជ្ជ។

ប្រព័ន្ធប្រតិបត្តិការហិរញ្ញវត្ថុតាម QR code នឹងជួយកម្ពុជាក្នុងការបង្កើនការប្រើប្រាស់រូបិយវត្ថុជាតិ(រៀល) និងជៀសវាងហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស។ ប្រជាជនកម្ពុជា និងថៃ អាចធ្វើដំណើរទៅកាន់ប្រទេសរបស់ខ្លួនទៅវិញទៅមកដោយពុំចាំបាច់ប្រើប្រាស់សាច់ប្រាក់ក្នុងការទូទាត់។

សេចក្តីប្រកាសនេះ គឺជាជំហានឆ្ពោះទៅរកការអនុវត្ត អនុស្សារណៈយោគយល់គ្នា (MOU) រវាងធនាគារជាតិនៃកម្ពុជាដែលបានចុះហត្ថលេខាជាមួយធនាគារជាតិថៃ ស្តីពី "កិច្ចសហប្រតិបត្តិការទំនើបភាវូបនីយកម្មហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សាច់ប្រាក់" ដែលផ្តោតទៅលើការពង្រីកកិច្ចសហប្រតិបត្តិការនៅក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសេវាទូទាត់

ដើម្បីបង្កើនប្រសិទ្ធផល និងសុវត្ថិភាពនៃការទូទាត់សាច់ប្រាក់ឆ្លងព្រំដែន ព្រមទាំងលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

### តារាងប្រចាំសប្តាហ៍៖ ចំណូលថវិកាថ្នាក់ខេត្ត គិតជាចំណែកតាមត្រីមាស ឆ្នាំ២០១៥ ដល់២០១៩

តារាងសម្រាប់សប្តាហ៍នេះបង្ហាញពីសមាមាត្រប្រចាំឆ្នាំនៃចំណូលថវិការថ្នាក់ខេត្ត ដែលទទួលបានក្នុងត្រីមាសនីមួយៗ ចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩។ ចំណូលថវិកាទទួលបានមានសមាមាត្រកាន់តែប្រហាក់ប្រហែលគ្នាពេញមួយឆ្នាំ ដោយសារតែនីតិវិធីរដ្ឋបាលមានភាពល្អប្រសើរជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ចំណូលភាគច្រើននៅតែទទួលបាននៅត្រីមាសចុងក្រោយនៃឆ្នាំនីមួយៗ។




ប្រភព៖ [ការអនុវត្តថវិកាឆ្នាំ ២០១៥-២០១៨ និងច្បាប់ថវិកាឆ្នាំ២០១៩]

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ទីផ្សារការងារនៅប្រទេសចិន ប្រឈមមុខនឹងសម្ពាធនៅក្នុងសង្គ្រាមពាណិជ្ជកម្មជាមួយអាមេរិក

ខណៈពេលដែលសង្គ្រាមពាណិជ្ជកម្មជាមួយអាមេរិកកំពុងអូសបន្លាយ ទីផ្សារការងាររបស់ចិនបង្ហាញសញ្ញានៃការធ្លាក់ចុះខ្សោយដែលបណ្តាលមកពីកង្វះខាតតម្រូវការ និងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ច។ ក្រុមហ៊ុនមួយចំនួននៅក្នុងប្រទេសចិនបានពន្យារពេល ឬបន្ថយកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការជ្រើសរើសនិស្សិតទើបបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យអោយចូលធ្វើការ ដោយពន្យារពេលជ្រើសរើសនិស្សិតដែលនៅក្នុងសាកលវិទ្យាល័យ។

យោងតាមលោក Liang Ming នាយកវិទ្យាស្ថានពាណិជ្ជកម្មអន្តរជាតិស្ថិតក្រោមក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា៖ វិស័យការងារអាចទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីការដាក់បន្ទឹងផ្នែកពាណិជ្ជកម្ម នៅពេលដែលក្រុមហ៊ុនមួយចំនួនផ្លាស់ប្តូរទីតាំងផលិតកម្មទៅកាន់ប្រទេសដទៃទៀតដែល មិនសូវមានការរឹតបន្តឹងពាណិជ្ជកម្ម។

យោងតាមស្ថាប័នផែនការសេដ្ឋកិច្ចជាន់ខ្ពស់របស់ចិនបានអោយដឹងថា សម្រាប់ពេលបច្ចុប្បន្ននេះ ស្ថានភាពការងារទូទៅសម្រាប់ឆ្នាំ២០១៩ នៅតែមានស្ថិរភាព ហើយចំនួនការងារដែលអាចរកបានគឺមានគ្រប់គ្រាន់។

## សេដ្ឋកិច្ចពិភពលោក

### កិច្ចប្រជុំកំពូល G-២០ រវាងចិន និងអាមេរិក អាចជះឥទ្ធិពលដល់ដំណើរការបន្ទាប់របស់ធនាគារកណ្តាលអាមេរិក

ធនាគារកណ្តាលរបស់អាមេរិក បានសម្រេចចិត្តរក្សាអត្រាការប្រាក់អោយនៅថេរកាលពីថ្ងៃពុធ ប៉ុន្តែបានបើកឱកាសសម្រាប់ការកាត់បន្ថយអត្រានេះ ប្រសិនបើសកម្មភាពសេដ្ឋកិច្ចចុះខ្សោយ។ យោងតាមលោក Rob Carnell ប្រធានសេដ្ឋវិទូ និងជាប្រធានស្រាវជ្រាវប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៅ ING បានឱ្យដឹងថា៖ កត្តាចម្បងមួយដែលជំរុញការសម្រេចចិត្តបន្ទាប់របស់ធនាគារកណ្តាលគឺ ប្រសិនបើកិច្ចប្រជុំកំពូល G-២០ រវាងមេដឹកនាំនៃប្រទេសមហាអំណាចសេដ្ឋកិច្ចធំទាំងពីរនៅលើពិភពលោកគឺចិន និងអាមេរិក បញ្ចប់ដោយគ្មានដំណោះស្រាយណាមួយចំពោះសង្គ្រាមពាណិជ្ជកម្ម។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ផលិតកម្មឧស្សាហកម្មនៅប្រទេសថៃ និងប្រទេសសឹង្ហបុរី អត្រានិកម្មភាព នៅប្រទេសជប៉ុន និងតៃវ៉ាន់ និងការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ប្រទេសថៃ។ ប្រទេសជប៉ុននឹងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូល G-២០ ដែលនឹងចាប់ផ្តើមនៅថ្ងៃសុក្រ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី២៤ មិថុនា ២០១៩

- តុល្យភាពពាណិជ្ជកម្មឥណ្ឌូនេស៊ី សម្រាប់ខែឧសភា
- សន្ទស្សន៍សេដ្ឋកិច្ចនាំមុខចុងក្រោយរបស់ជប៉ុន សម្រាប់ខែមេសា
- អត្រាអតិផរណារបស់សឹង្ហបុរី សម្រាប់ខែឧសភា
- អត្រានិកម្មភាពរបស់តៃវ៉ាន់ សម្រាប់ខែឧសភា

ថ្ងៃអង្គារ ទី២៥ មិថុនា ២០១៩

- ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់របស់កូរ៉េខាងត្បូង សម្រាប់ខែមិថុនា
- ផលិតកម្មឧស្សាហកម្មរបស់ថៃ សម្រាប់ខែឧសភា
- សមតុល្យថវិការបស់ហ្វីលីពីន សម្រាប់ខែឧសភា
- ការលក់ផ្ទះថ្មីនៅអាមេរិក សម្រាប់ខែឧសភា

ថ្ងៃពុធ ទី២៦ មិថុនា ២០១៩

- អត្រាអតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែឧសភា
- ផលិតកម្មឧស្សាហកម្មរបស់សឹង្ហបុរី ធៀបនឹងឆ្នាំមុនសម្រាប់ខែឧសភា
- ការសម្រេចចិត្តទៅលើអត្រាការប្រាក់របស់ថៃ

ថ្ងៃព្រហស្បតិ៍ ទី២៧ មិថុនា ២០១៩

- ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់របស់តៃវ៉ាន់ សម្រាប់ខែមិថុនា
- ការលក់រាយរបស់ជប៉ុន សម្រាប់ខែឧសភា
- ប្រាក់ចំណេញផ្នែកឧស្សាហកម្មរបស់ចិន សម្រាប់ខែឧសភា
- សន្ទស្សន៍ថ្លៃការផលិតរបស់ម៉ាឡេស៊ី សម្រាប់ខែឧសភា
- អត្រាកំណើនសេដ្ឋកិច្ចរបស់អាមេរិក ចុងក្រោយ សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩

ថ្ងៃសុក្រ ទី២៨ មិថុនា ២០១៩

- ផលិតកម្មឧស្សាហកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែឧសភា
- គណនីចរន្តរបស់ថៃ សម្រាប់ខែឧសភា
- ផលិតកម្មឧស្សាហកម្មវៀតណាម សម្រាប់ខែមិថុនា
- ប្រាក់ចំណូលបុគ្គលនៅអាមេរិក សម្រាប់ខែឧសភា
- អត្រានិកម្មភាពរបស់ជប៉ុន សម្រាប់ខែឧសភា
- កិច្ចប្រជុំកំពូល G-២០ នៅប្រទេសជប៉ុន